International Labour Organization



**ការកសាងភាពធន់ក្នុងអំឡុងពេល និងក្រោយការរាតត្បាតនៃមេរោគកូវីដ-១៩**

គោលការណ៍ណែនាំអំពីកូវីដ-១៩ និងបញ្ជីសកម្មភាព

សម្រាប់រោងចក្រកាត់ដេរ និងអ្នកគ្រប់គ្រង

# ការកាត់បន្ថយចំណាយ

សម្រាប់ឱ្យរោងចក្រកាត់ដេរដោះស្រាយវិបត្តិនៃជំងឺកូវីដ-១៩ គោលការណ៍ណែនាំនេះជួយអ្នកគ្រប់គ្រងរោងចក្រឱ្យកាត់បន្ថយចំណាយដើម្បីសម្រួលដល់សន្ទនីយភាពហិរញ្ញវត្ថុ និងសម្ពាធលំហូរសាច់ប្រាក់លើប្រតិបត្តិការរោងចក្ររបស់ពួកគេ។

## ការចាប់ផ្តើម

រួមមាន៖
គំរូបញ្ជីទិន្នន័យចំណាយ បញ្ជីផ្ទៀងផ្ទាត់សកម្មភាព

**គោលការណ៍ណែនាំនេះផ្តោតលើ៖**

- ហេតុអ្វីការគ្រប់គ្រងចំណាយមានសារៈសំខាន់ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺនេះ
- ប្រភេទនៃការចំណាយក្នុងវិស័យកាត់ដេរ
- វិធី ៨ យ៉ាងដែលរោងចក្រអាចកាត់បន្ថយចំណាយប្រកបដោយទំនួលខុសត្រូវសង្គម

## 1. ហេតុអ្វីការគ្រប់គ្រងចំណាយមានសារៈសំខាន់ក្នុងពេលមានវិបត្តិនៃជំងឺនេះ

ការរីករាលដាននៃជំងឺកូវីដ-១៩ ប្រហែលជាធ្វើឱ្យរោងចក្ររបស់អ្នកស្ថិតនៅក្នុងស្ថានភាពហិរញ្ញវត្ថុដ៏លំបាក ដោយការបញ្ជាទិញត្រូវបានលុបចោល ហើយការទទួលប្រាក់ចំណូលបានតិចជាងមុន។ នឹងមានសំពាធហិរញ្ញវត្ថុច្រើនប្រភេទនៅក្នុងរោងចក្ររបស់អ្នក។ ការទូទាត់វិក័យប័ត្រដល់

"

# ការកសាងភាពធន់ក្នុងអំឡុងពេល និងក្រោយការរាតត្បាតនៃមេរោគកូវីដ-១៩

អ្នកផ្គត់ផ្គង់របស់អ្នកសម្រាប់វត្ថុធាតុដើមដែលអ្នកបានបញ្ជាទិញ ដូចជាក្រណាត់ គ្រឿងលម្អ ឬសម្ភារៈវេចខ្ចប់ អាចជាបញ្ហាប្រឈម ឬពេលខ្លះមិនអាចធ្វើទៅរួចផង។ រោងចក្រដូចជារោងចក្រ FOB ដែលផ្គត់ផ្គង់ក្រណាត់ដោយខ្លួនឯងត្រូវបានទទួលរងសម្ពាធហិរញ្ញវត្ថុជាពិសេស។



ការបើកប្រាក់ខែឱ្យកម្មកររបស់អ្នកក៏នឹងជាការលំបាកដែរក្នុងគ្រាដែលមានកម្រិតសាច់ប្រាក់ទាប។ បញ្ហាប្រឈមមួយទៀតគឺការបង់វិក័យប័ត្រប្រើប្រាស់ទឹកភ្លើងអគ្គិស នីឬហ្គាស។ ដូច្នេះ ខណៈដែលអ្នកអាចត្រូវកាត់បន្ថយចំណាយដើម្បីការពារអាជីវកម្មរបស់អ្នកនាពេលអនាគតដ៏ខ្លីខាងមុខ កូវីដ-១៩ ក៏ផ្តល់ឱកាសដើម្បីធ្វើឱ្យប្រតិបត្តិការរបស់អ្នកកាន់តែមានប្រសិទ្ធិភាពចំណាក្នុងរយៈពេលវែងផងដែរ។

អនុសាសន៍នៅក្នុងគោលការណ៍ណែនាំនេះនឹងជួយអ្នកក្នុងការកាត់បន្ថយចំណាយប្រកបដោយទំនួលខុសត្រូវសង្គម។ ក្នុងការធ្វើដូច្នេះ ប្រតិបត្តិករកាត់ដេរនៅទីបំផុតអាច៖

- ផ្តោតលើការថែរក្សាប្រតិបត្តិការ និងកាត់បន្ថយភាពតានតឹងលើរោងចក្រក្នុងរយៈពេលវែង
- កសាងភាពធន់ក្នុងអំឡុងពេល និងក្រោយការរាតត្បាតនៃមេរោគកូវីដ-១៩ និង
- បង្កើនភាពប្រកួតប្រជែងរបស់ពួកគេនាពេលអនាគត។

## ២- ការបង្ហាញមុខចំណាយក្នុងវិស័យកាត់ដេរ

មុននឹងចាប់ផ្តើមធ្វើសកម្មភាព វាជាការចាំបាច់ដែលត្រូវដឹងថាតើអ្នកចំណាយលើអ្វីខ្លះ និងថាតើវាអាចជះឥទ្ធិពលយ៉ាងដូចម្តេចដល់អាជីវកម្ម និងប្រតិបត្តិការរោងចក្ររបស់អ្នក ក្នុងស្ថានភាពនៃជំងឺរាតត្បាត។ រោងចក្រកាត់ដេរប្រឈមនឹងការចំណាយជាច្រើន ដែលជាធម្មតាអាចត្រូវបានបំបែកជាបីប្រភេទធំៗគឺ៖

**ចំណាយលើវត្ថុធាតុដើម៖** អាស្រ័យលើគំរូនៃការផ្គត់ផ្គង់ ឧ. អ្នកទិញទទួលខុសត្រូវលើទំនិញចាប់ពីចំណុចដឹកជញ្ជូន (FOB)/កញ្ចប់ទំនិញពេញ (FOB) ឬរោងចក្រកាត់-ផលិត-លម្អ (CMT) អាចនឹងរ៉ាប់រងលើចំណាយវត្ថុធាតុដើមដែលប្រើក្នុងផលិតកម្ម។

**ចំណាយលើកំលាំងពលកម្ម៖** ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលពាក់ព័ន្ធនឹងដំណើរការផលិត ដូចជាប្រតិបត្តិករ។

**ចំណាយប្រតិបត្តិការប្រចាំថ្ងៃ៖** នេះជាចំណាយនានាសម្រាប់ធ្វើឱ្យរោងចក្រដំណើរការ ប៉ុន្តែវាមិនទាក់ទងដោយផ្ទាល់ទៅនឹងការផលិតរបស់រោងចក្ររបស់អ្នកទេ ដូចជាការជួល និងចំណាយទឹកភ្លើង។

ការចំណាយរបស់រោងចក្រក៏អាចត្រូវបានបែងចែកជាចំណាយថេរ និងចំណាយអថេរ ផងដែរ៖

**ចំណាយថេរ**មិនផ្លាស់ប្តូរតាមការប្រែប្រួលនៃបរិមាណផលិតកម្មរបស់អ្នកទេ។ មិនថារោងចក្ររបស់អ្នកផលិតបានប៉ុន្មានក្នុងមួយខែៗទេ ចំណាយថេររបស់អ្នកនឹងនៅដដែល។ ថ្លៃដើមថេររួមមានដូចជាការជួលអគាររោងចក្រ ពន្ធលើអចលនទ្រព្យ ការធានារ៉ាប់រង សន្តិសុខ ចំណាយលើម៉ាស៊ីន និងឧបករណ៍ ចំណាយលើការអនុលោមតាមច្បាប់ ជាដើម។

ផ្ទុយទៅវិញ **ចំណាយអថេរ** គឺពាក់ព័ន្ធនឹងការថយចុះ/ការកើនឡើងនៃផលិតកម្មរោងចក្ររបស់អ្នក។ ចំណាយអថេររួមមាន ឧ. ប្រាក់ឈ្នួលកម្មករនិយោជិត ចំណាយទឹកភ្លើង សារធាតុគីមី។ ល។

> តើចំណាយអ្វីខ្លះ ដែលជាចំណាយធំៗនៅក្នុងរោងចក្ររបស់អ្នក?

ការចំណាយក៏អាស្រ័យលើរោងចក្រផ្ទាល់ ទីតាំងរបស់រោងចក្រ និងគំរូរកនៃការផ្គត់ផ្គង់ដែលដែលរោងចក្រអនុវត្ត។ សម្រាប់រោងចក្រដែលទិញក្រណាត់ផ្ទាល់ ការចំណាយលើវត្ថុធាតុដើមមានចំនួនប្រមាណជា ២ ភាគ ៣ នៃចំណាយសរុប ខណៈថ្លៃកំលាំងពលកម្ម
និងចំណាយប្រតិបត្តិការប្រចាំថ្ងៃ នីមួយៗ មានចំនួនមួយភាគប្រាំ ដូចបង្ហាញក្នុងរូបខាងក្រោម។

សម្រាប់រោងចក្រកាត់ដេរដែលប្រតិបត្តិការក្រោមគំរូ CMT និងប្រើប្រាស់សម្ភារៈដែលផ្តល់ដោយអតិថិជន ថ្លៃកំលាំងពលកម្មមានប្រមាណពី ៥0 ទៅ ៦0 ភាគរយនៃចំណាយសរុប ខណៈដែលចំណាយប្រតិបត្តិការប្រចាំថ្ងៃមានចន្លោះពី ៣0 ទៅ ៤0 ភាគរយ (ដូចបង្ហាញខាងក្រោម) ។ ចំណាយលើគ្រឿងបន្ថែម ដូចជាខ្សែអំបោះ ម្ជុល និងខ្សែរូត មានចំនួន ១០ ភាគរយ។

**មុខចំណាយជាទូទៅរបស់រោងចក្រ**
**ដែលអនុវត្តគំរូ FOB**




**មុខចំណាយជាទូទៅរបស់រោងចក្រ**
**ដែលអនុវត្តគំរូ CMT**




## 3. ត្រៀមខ្លួនសម្រាប់សកម្មភាព

ដោយសារអ្នកបានពិនិត្យនូវប្រភេទនៃការចំណាយដែលពាក់ព័ន្ធនឹងប្រតិបត្តិការរោងចក្រកាត់ដេរ ហើយ ផ្នែកបន្ទាប់នឹងផ្តល់នូវជំហានជាក់លាក់មួយចំនួនស្តីពីការគ្រប់គ្រងចំណាយ ដោយធ្វើវាប្រកបដោយទំនួលខុសត្រូវសង្គម។



# វិធី ៨ យ៉ាងដែលរោងចក្រអាចកាត់បន្ថយចំណាយប្រកបដោយទំនួលខុសត្រូវសង្គម

**០១ ត្រួតពិនិត្យចំណាយរបស់អ្នក**
បង្កើតរូបភាពនៃការចំណាយលឱ្យបានច្បាស់លាស់ និងលម្អិត

**០២ ផ្តោតលើលទ្ធផលដែលងាយទទួលបាន**
កំណត់ចំណាយដែលអ្នកអាចកាត់បន្ថយបានងាយស្រួល និងភ្លាមៗ

**០៣ លុបបំបាត់នូវអ្វីដែលមិនបន្ថែមតម្លៃ**
កាត់បន្ថយអ្វីដែលមិនចាំបាច់

**០៤ កាត់បន្ថយចំណាយលើវត្ថុធាតុដើម**
រកវិធីសន្សំលើវត្ថុធាតុដើម និងក្រណាត់

**០៥ ពិចារណា និងបង្កើតថ្មីឡើងវិញនូវសារពើភ័ណ្ឌរបស់អ្នក**
រក្សាសារពើភ័ណ្ឌឱ្យក្នុងកម្រិតអប្បបរមាហើយរកមើលជម្រើសជំនួសកន្លែងស្តុក

**០៦ ស្វែងរកមធ្យោបាយផ្សេងៗដើម្បីកាត់បន្ថយចំណាយ**
កាត់បន្ថយចំណាយប្រចាំខែ និងចរចាចំណាយថេរ ដូចជាការជួល

**០៧ កាត់បន្ថយផលប៉ះពាល់លើកម្មករ**
ពិចារណាជម្រើសទាំងអស់ដើម្បីបញ្ចៀសការបញ្ឈប់ពីការងារ និងបន្តជូនដំណឹងដល់បុគ្គលិក

**០៨ គាំទ្រគ្នាទៅវិញទៅមក**
ធ្វើការរួមគ្នាជាមួយរោងចក្រ សមាគម និងឧស្សាហកម្មដទៃទៀត

# ចាប់ផ្ដើមអនុវត្តផែនការ៖ បញ្ជីត្រួតពិនិត្យរោងចក្រ

## 1. ពិនិត្យចំណាយរបស់អ្នក

Factory_Cash_Flo Template.xlsx

ចាប់ផ្ដើមដោយចំណាយពេលខ្លះដើម្បីពិនិត្យមើលកំណត់ត្រាហិរញ្ញវត្ថុរបស់អ្នក។ អ្នកមិនអាចកាត់បន្ថយចំណាយបានទេ ប្រសិនបើអ្នកមិនដឹងថាចំណាយរបស់អ្នកមានអ្វីខ្លះនោះ។ **គន្លឹះមានប្រយោជន៍៖** ប្រើគំរូសន្លឹកឯកសារស្ដីពីចំណាយដែលមានភ្ជាប់ (នៅខាងស្ដាំ) ដើម្បីជួយអ្នកក្នុងការបង្ហាញចំណាយរបស់អ្នក។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| ដើម្បីពិនិត្យមើលការចំណាយថេររបស់អ្នក<br>សូមមើលកំណត់ត្រាហិរញ្ញវត្ថុរបស់អ្នកដោយគិតពីសំណួរខាងក្រោម៖<br>▶ តើយើងចំណាយលើអ្វីខ្លះជាទៀងទាត់រៀងរាល់ខែ ដែលឯករាជ្យពីផលិតកម្មរបស់យើង?<br>▶ តើយើងចំណាយប៉ុន្មានសម្រាប់មុខចំណាយនីមួយៗក្នុងមួយខែៗ? | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| ដើម្បីពិនិត្យមើលការចំណាយអថេររបស់អ្នក សូមមើលកំណត់ត្រាហិរញ្ញវត្ថុរបស់អ្នកដោយគិតពីសំណួរខាងក្រោម៖<br>▶ តើការចំណាយណាខ្លះដែលប្រែប្រួលទៅតាមទិន្នផលរបស់យើង? ដូចដែលបានបញ្ជាក់ខាងលើ វាអាចជាប្រាក់ឈ្នួលរបស់កម្មករ ចំណាយទឹកភ្លើង ឬសារធាតុគីមីរបស់អ្នក។ ល។<br>▶ បន្ទាប់មក អ្នកត្រូវដឹងថាអ្នកចំណាយប៉ុន្មានសម្រាប់ផលិតផលនីមួយៗ។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |

## 2. ផ្ដោតលើលទ្ធផលដែលងាយទទួលបាន

ជំហ៊ានទី ២ យើងនឹងផ្ដោតលើជោគជ័យរហ័សដែលរោងចក្ររបស់អ្នកអាចសម្រេចបាន។ សម្រាប់ចំណុចនេះ សូមព្យាយាមកំណត់មុខចំណាយដែលអ្នកអាចកាត់បន្ថយបានយ៉ាងស្រួល ឬដែលអ្នកអាចកាត់បន្ថយបានភ្លាមៗទាំងនោះ។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នក ឬគំរូដែលបានបំពេញ សូមកំណត់ចំណាយដែលមិនចាំបាច់សម្រាប់រោងចក្ររបស់អ្នកដើម្បីរក្សាប្រតិបត្តិការ ប៉ុន្តែវាពាក់ព័ន្ធនឹងសកម្មភាពមិនសូវសំខាន់។ ការចំណាយទាំងនេះអាចរាប់បញ្ចូលទាំងចំណាយលើឧបករណ៍ សម្ភារៈការិយាល័យ។ ល។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| រកវិធីកាត់ ឬបន្ថយចំណាយឱ្យបានឆាប់បំផុត។ | ✓✓ | »» រយៈពេលខ្លី | ☐ |

## 3. លុបបំបាត់អ្វីដែលមិនបន្ថែមតម្លៃ

បើចាំបាច់ អ្នកក៏គួររកវិធីលុបបំបាត់សកម្មភាពដែលមិនបង្កើតប្រាក់ចំណេញពីមុនមក។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| ពិនិត្យមើលមុខផលិតផល និងសកម្មភាពរបស់អ្នកនៅក្នុងរោងចក្រដើម្បីរកមើលប្រាក់ចំណេញរបស់វា។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |

| | | | |
|---|---|---|---|
| សូមក្រឡេកមើលមុខផលិតផលរបស់អ្នក (អាវ ខោ  អាវកាក់ អាវយឺត។ ល។ ) និងគណនាប្រាក់ចំណេញរបស់វាក្នុងមួយមុខៗ សម្រាប់ការបញ្ជាទិញនីមួយៗ។<br>លុបបំបាត់មុខផលិតផល និងសកម្មភាពដែលមិនផ្តល់ប្រាក់ចំណេញល្អដូចមុខផលិតផលផ្សេងទៀត ក្នុងរយៈពេលប្រាំមួយខែចុងក្រោយ ហើយកុំស្ទាក់ស្ទើរក្នុងការធ្វើដូច្នេះ ព្រោះវានឹងកាន់តែពិបាកក្នុងការស្តារស្ថានការចេញពីវិបត្តិនេះ ប្រសិនបើអ្នកបន្តអូសបន្លាយកាន់តែយូរនោះ។ | ✓✓ | »» »»<br>រយៈពេលមធ្យម | ☐ |

## 4. កាត់បន្ថយចំណាយលើវត្ថុធាតុដើម

ប្រសិនបើរោងចក្ររបស់អ្នកទិញក្រណាត់ខ្លួនឯង វាទំនងជាចំណាយមួយភាគធំនៃការចំណាយប្រចាំខែសរុបរបស់អ្នក។ ដូច្នេះ ការកាត់បន្ថយចំណាយលើវត្ថុធាតុដើមគួរតែជាអាទិភាពសម្រាប់អ្នក នៅពេលអ្នកបន្ត ឬដំណើរការឡើងវិញនូវប្រតិបត្តិការរោងចក្រ។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| កុំខ្លាចសុំការបញ្ចុះតម្លៃ។ ត្រូវចរចាយកការទិញ/លក់ល្អបំផុតដែលអាចធ្វើបាន។ | ✓✓✓ | »»<br>រយៈពេលខ្លី | ☐ |
| សួរអ្នកផ្គត់ផ្គង់ជាច្រើន (ឧទាហរណ៍ សួររហូតដល់ប្រាំក្រុមហ៊ុន) ដើម្បីឱ្យពួកគេផ្ញើសម្រង់តម្លៃមកអ្នក នៅពេលរកប្រភពផ្គត់ផ្គង់វត្ថុធាតុដើម។ | ✓✓ | »»<br>រយៈពេលខ្លី | ☐ |
| សូមមើលបច្ចេកទេសកាត់បន្ថយសំណល់វត្ថុធាតុដើមប ក្នុងផលិតកម្មរបស់អ្នក (ឧទាហរណ៍ មើលប្រតិបត្តិការបន្ទប់កាត់របស់អ្នក - ការលាតក្រណាត់ជាប្រព័ន្ធបង្កើនប្រសិទ្ធភាពទំហំគំនូសលើក្រណាត់ % បង្កើនការប្រើប្រាស់ក្រណាត់ % ។ ល។ ) ។ | ✓ | »»<br>រយៈពេលខ្លី | ☐ |
| ពិចារណាថាតើអ្នកអាចប្រើក្រណាត់ជំនួស (ថោកជាង) ដោយមិនប៉ះពាល់ដល់គុណភាពផលិតផលឬទេ។ | ✓✓ | »» »»<br>រយៈពេលមធ្យម | ☐ |
| កសាងទំនាក់ទំនងយូរអង្វែងជាមួយអ្នកផ្គត់ផ្គង់វត្ថុធាតុដើម និងគ្រឿងលម្អរបស់អ្នក ដែលទំនាក់ទំនងនេះត្រូវកសាងឡើងដោយការយោគយល់គ្នា។ ទំនាក់ទំនងល្អនឹងបង្កើតឱ្យមានស្ថានភាពឈ្នះឈ្នះសម្រាប់អ្នក និងអ្នកផ្គត់ផ្គង់ ដែលក្នុងនោះអ្នកនឹងអាចទទួលបានការផ្គត់ផ្គង់វត្ថុធាតុដើមក្នុងតម្លៃទាប ហើយអ្នកផ្គត់ផ្គង់នឹងមានអតិថិជនយូរអង្វែង។ | ✓ | »» »» »»<br>រយៈពេលវែង | ☐ |

## 5. ពិចារណា និងបង្កើតថ្មីឡើងវិញនូវសារពើភ័ណ្ឌរបស់អ្នក

នៅក្នុងពេលនៃវិបត្តិកូវីដ-១៩ នេះ រោងចក្រកាត់ដេរជាច្រើនបានទទួលរងផលប៉ះពាល់ដោយសារការបញ្ជាទិញត្រូវបានលុបចោល ឬផ្អាក។ កត្តានេះបាននាំឱ្យវត្ថុធាតុដើមជាច្រើនមិនអាចត្រូវបានប្រើប្រាស់។ ដោយសារការទិញវត្ថុធាតុដើមត្រូវការចំណាយច្រើន វាការចំណាយផ្សេងៗទៀត ឧទាហរណ៍ សម្រាប់បុគ្គលិក ការធានារ៉ាប់រង ការកត់ត្រាស្តុក ថ្លៃអគ្គិសនី និងការថែទាំនានានឹងនាំឱ្យចំណាយកើនឡើងនាពេលខាងមុខ។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| រក្សាការផ្ទុករបស់អ្នកឱ្យមានរបៀបរៀបរយ។ វានឹងធ្វើឱ្យប្រតិបត្តិការរបស់អ្នកកាន់តែមានប្រសិទ្ធភាព ហើយនឹងជួយកាត់បន្ថយការចំណាយដែលមិនចាំបាច់ ដោយបញ្ចៀសនូវការខូចខាតសម្ភារៈមានតម្លៃ។ | ✓✓✓ | »»<br>រយៈពេលខ្លី | ☐ |
| ប្រសិនបើអ្នកមានវត្ថុធាតុដើមដែលនៅសល់ដោយសារការបញ្ជាទិញត្រូវបានលុបចោល សូមពិភាក្សាជាមួយអ្នកទិញរបស់អ្នកអំពីរបៀបដែលអ្នកអាចប្រើវត្ថុធាតុដើមទាំងនោះ ហើយកុំទុកឱ្យវាខ្ជះខ្ជាយចោល។ ការចរចារកិច្ចសន្យាអាចមានភាពខុសប្លែកគ្នានៅក្នុងបញ្ហានេះ ប៉ុន្តែអ្នកគួរ | ✓✓ | »»<br>រយៈពេលខ្លី | ☐ |

| | | | |
|---|---|---|---|
| តែជំរុញឱ្យអ្នកទិញរបស់អ្នកអនុញ្ញាតឱ្យអ្នកទទួលបានអត្ថប្រយោជន៍ជាអតិបរមា (ដឹកជញ្ជូនលើសការអនុញ្ញាត ៣% ឬ ៥%) ដើម្បីឱ្យអ្នកអាចរក្សាជីវិតអាជីវកម្មក្នុងគ្រាពិបាកនេះ។ | | | |
| ប្រសិនបើអ្នកមិនអាចប្រើវត្ថុធាតុដើមដែលនៅសល់ឡើងវិញទេ សូមពិចារណាកែច្នៃវា។ បច្ចុប្បន្នមានឱកាសក្នុងការកែច្នៃវត្ថុធាតុដើមឡើងវិញតាមរយៈវេទិកាផ្សេងៗ។ សូមជជែកជាមួយសមាគមកាត់ដេររបស់អ្នកអំពីឱកាសដែលមានស្រាប់នៅក្នុងប្រទេសរបស់អ្នក (ផលិតរបស់របរសម្រាប់ទីផ្សារក្នុងស្រុក ប៉ុន្តែត្រូវពិនិត្យលើទិដ្ឋភាពច្បាប់ជាមុន) ។ | ✓✓ | »» »» រយៈពេលមធ្យម | ☐ |
| ប្រសិនបើអ្នកមិនអាចប្រើ ឬកែច្នៃក្រណាត់របស់អ្នកឡើងវិញទេ សូមព្យាយាមចោលវាប្រកបដោយភាតរៈបរិស្ថាន ព្រោះវានឹងត្រូវការទីតាំងស្តុកនៅក្នុងឃ្លាំងរបស់អ្នក និងធ្វើឱ្យអ្នកខាតបង់ថវិកាច្រើននាពេលខាងមុខ។ | ✓✓ | »» »» រយៈពេលមធ្យម | ☐ |
| ចាប់ផ្តើមអនុវត្តគំរូដែលនឹងជួយអ្នកឱ្យរក្សាកម្រិតស្តុកល្អបំផុត ដូចជាស្តុកតាមសេចក្តីត្រូវការ (Just-In-Time) និង / ឬ បរិមាណបញ្ជាទិញសេដ្ឋកិច្ច (EOQ)។ | ✓ | »» »» »» រយៈពេលវែង | ☐ |

## 6. ស្វែងរកវិធីដើម្បីកាត់ចំណាយប្រតិបត្តិការប្រចាំថ្ងៃ

មិនថាប្រតិបត្តិការរបស់អ្នកត្រូវបានរាំងស្ទះ ឬត្រូវបានផ្អាកទេ អ្នកនឹងនៅតែត្រូវរ៉ាប់រងចំណាយថេររបស់អ្នក។ ព្យាយាមចរចាលើការចំណាយថេររបស់អ្នកឡើងវិញ។ រកមើលទាំងដំណោះស្រាយរយៈពេលខ្លី ដូចជាការបញ្ចុះថ្លៃឈ្នួលជាបណ្តោះអាសន្ន ក៏ដូចជាដំណោះស្រាយរយៈពេលវែងនានា។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| កាត់បន្ថយការចំណាយទឹកភ្លើងរបស់អ្នក ដោយការប្រើប្រាស់អគ្គិសនី ទឹក និងហ្គាសតិចជាងមុន (ឧទាហរណ៍៖ ប្រើម៉ាស៊ីនដែលដំណើរការដោយម៉ូទ័រផ្ទាល់ ប្រើរ៉ូប៊ីណេបើកទឹកជាន់ដោយជើងតាមភាពសមស្រប បិទភ្លើងក្នុងបន្ទប់ដែលមិនប្រើ តំឡើងសន្លឹកដំបូលថ្លាសម្រាប់បំភ្លឺដោយធម្មជាតិ។ ល។ ) ។ | ✓✓ | »» រយៈពេលខ្លី | ☐ |
| ទាក់ទងម្ចាស់ដី/អាគាររបស់អ្នកដើម្បីស្នើសុំចរចា ឬបង្អកការជួលជាបណ្តោះអាសន្ន។ | ✓ | »» រយៈពេលខ្លី | ☐ |
| ទូរស័ព្ទទៅអ្នកក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកដើម្បីពិនិត្យមើលថាតើពួកគេមានការផ្តល់ជូនប្រសើរជាងមុនសម្រាប់អ្នកដែរឬទេ។ | ✓ | »» រយៈពេលខ្លី | ☐ |
| ជជែកជាមួយសមាគមកាត់ដេររបស់អ្នកសម្រាប់ការណែនាំទាក់ទងនឹងពន្ធរបស់រដ្ឋាភិបាល និងកម្មវិធី / ឧបត្ថម្ភធនរដ្ឋាភិបាលផ្សេងទៀត ដែលត្រូវបានណែនាំក្នុងកំឡុងពេលនៃ វិបត្តិនេះ។ | ✓✓ | »» រយៈពេលខ្លីដល់រយៈពេលមធ្យម | ☐ |
| ជជែកជាមួយធនាគាររបស់អ្នកដើម្បីពិនិត្យមើលថាតើពួកគេអាចផ្តល់អត្រាទាបសម្រាប់សេវាកម្មហិរញ្ញវត្ថុរបស់ពួកគេ ដូចជាលិខិតឥណទាន ឬប្រាក់កម្ចីបានដែរឬទេ។ | ✓ | »» »» រយៈពេលមធ្យម | ☐ |

## 7. កាត់បន្ថយផលប៉ះពាល់លើកម្មករ

ការរាតត្បាតនៃមេរោគកូវីដ-១៩ អាចបង្ខំឱ្យអ្នកត្រូវកាត់បន្ថយកម្លាំងពលកម្មរបស់អ្នក។ ប្រសិនបើដូច្នេះ ត្រូវប្រាកដថាអ្នកធ្វើវាប្រកបដោយទំនួលខុសត្រូវសង្គម។ ការបញ្ឈប់ការងារបុគ្គលិកនឹងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កម្មករ/និយោជិតរបស់អ្នក ហើយអ្នកគួរតែពិចារណាពីវិធីដែលអ្នកអាចកាត់បន្ថយផលប៉ះពាល់នេះឱ្យបានច្រើនបានតាមដែលអាចធ្វើទៅបាន។ សម្រាប់ការណែនាំបន្ថែមស្តីពីវិធីដោះស្រាយប្រកបដោយទំនួលខុសត្រូវជាមួយការបញ្ឈប់ពីការងារ ក្នុងកំឡុងពេលនៃវិត្តិកូវីដ-១៩ សូមចុច ត្រង់នេះ។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|

| | | | |
|---|---|---|---|
| ស្វែងរកដំបូន្មានពីសមាគមរោងចក្រកាត់ដេររបស់អ្នកអំពីលទ្ធភាពដែលអ្នកមាន មុនពេលចាប់ផ្តើមបញ្ឈប់បុគ្គលិក ឬកាត់បន្ថយប្រតិបត្តិការ។ | ✓✓✓ | »»» រយៈពេលខ្លី | ☐ |
| ក្នុងករណីណាក៏ដោយ អាជីវកម្មត្រូវតែគោរពតាមច្បាប់និងបទប្បញ្ញត្តិជាតិ ក៏ដូចជាស្តង់ដារពលកម្មអន្តរជាតិដែរ។ | ✓✓✓ | »»» រយៈពេលខ្លី | ☐ |
| ពិគ្រោះយោបល់ជាមួយកម្មករមុនពេលចាត់វិធានការណាមួយទាក់ទងនឹងការបញ្ឈប់ពីការងារ។ | ✓✓✓ | »»» រយៈពេលខ្លី | ☐ |
| ផ្តល់ព័ត៌មានពាក់ព័ន្ធដល់តំណាងកម្មករ និងឱ្យពួកគេចូលរួមក្នុងកិច្ចពិភាក្សាទាក់ទងនឹងវិធានការណ៍នានា ដើម្បីបញ្ចៀសការបញ្ចប់កិច្ចសន្យាការងារ ក៏ដូចជាការកាត់បន្ថយផលប៉ះពាល់នានា។ | ✓✓✓ | »»» រយៈពេលខ្លី | ☐ |
| ធានាថារោងចក្ររបស់អ្នកមានព័ត៌មានអំពីវិធានការរបស់រដ្ឋាភិបាល ការគាំពារសង្គម និងការគាំទ្រដល់កម្មករនិយោជិត ហើយផ្តល់ព័ត៌មានទាំងនោះដល់កម្មករ។ | ✓✓✓ | »»» រយៈពេលខ្លី | ☐ |

## 8. គាំទ្រគ្នាទៅវិញទៅមក

ការសហការគ្នាជាមួយរោងចក្រផ្សេងទៀត និងសមាគមរបស់អ្នកអាចជួយអ្នកក្នុងការកាត់បន្ថយចំណាយ និងបង្ហាញជំហររួមរបស់ឧស្សាហកម្មទៅដល់អ្នកទិញ/ម៉ាកយីហោ រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងឧស្សាហកម្ម។

ការរាតត្បាតនៃមេរោគកូវីដ-១៩ នឹងប៉ះពាល់យ៉ាងខ្លាំងដល់រោងចក្ររបស់អ្នក ក៏ដូចជារោងចក្ររបស់ផ្សេងទៀតដែរ។ នេះគឺជាពេលវេលាដែលត្រូវមានសាមគ្គីភាព និងដើម្បីឱ្យវិស័យកាត់ដេរជៀសផុតពីវិបត្តិនេះ ដោយធ្វើការរួមគ្នាជាមួយរោងចក្រដទៃទៀត។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| ទាក់ទងជាមួយរោងចក្រផ្សេងទៀតដើម្បីស្វែងយល់ពីស្ថានភាពរបស់ពួកគេ និងស្វែងយល់ពីរបៀបដែលអ្នកអាចសហការគ្នា | ✓✓✓ | »»» រយៈពេលខ្លី | ☐ |
| ទិញវត្ថុធាតុដើមរួមគ្នាដើម្បីអាចទិញបានក្នុងតម្លៃទាប។ | ✓✓ | »»» រយៈពេលខ្លី | ☐ |
| ទិញសម្ភារៈ និងធាតុចូលពីគ្នាទៅវិញទៅមក បើអាចធ្វើបាន ដើម្បីកាត់បន្ថយផលប៉ះពាល់ពីការបញ្ជាទិញដែលត្រូវបានលុបចោល ដែលធ្វើឱ្យរោងចក្រសល់ក្រណាត់។ | ✓✓ | »»» រយៈពេលខ្លី | ☐ |
| ស្វែងរកឱកាសធ្វើការផ្លាស់ប្តូរជាមួយគ្នាដើម្បីទទួលបានឧបករណ៍ដែលត្រូវការ។ | ✓✓ | »»» »»» រយៈពេលមធ្យម | ☐ |
| ចូលរួមជាមួយគ្នាក្នុងការងារសមាគមរោងចក្រកាត់ដេររបស់អ្នកដើម្បីពង្រឹងភាពប្រកួតប្រជែង និងភាពធន់នៃវិស័យកាត់ដេររបស់ប្រទេសអ្នក។ | ✓✓✓ | »»» »»» រយៈពេលមធ្យម | ☐ |

គោលការណ៍ណែនាំទាំងនេះត្រូវបានរៀបចំឡើងដោយនាយកដ្ឋានសហគ្រាសរបស់អង្គការ ILO សម្រាប់ **គម្រោងការងារសមរម្យនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់វិស័យកាត់ដេរនៅអាស៊ី** ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលស៊ុយអែត។

សម្រាប់ឯកសារ ឬធនធានផ្សេងៗទៀតដើម្បីជួយអ្នកដោះស្រាយស្ថានភាពក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ សូមចូលទៅកាន់៖

▶ ilo.org/covid19


**ក្រុមការងារគាំទ្របច្ចេកទេសគម្រោងការងារសមរម្យ**
**សម្រាប់តំបន់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក**
អគារអង្គការសហប្រជាជាតិ ជាន់ទី ១០ ផ្លូវ Rajdamnern Nok
ទីក្រុងបាងកក ១០២០០ ប្រទេសថៃ
ទូរស័ព្ទលេខ៖ ៦៦២ ២៨៨ ១២៣៤ ទូរសារ៖ ៦៦២ ២៨៨ ៣០៥៨
អ៊ីម៉ែល៖ BANGKOK@ilo.org


DECENT WORK
A better world starts here.